**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

## ផ្ញើជូន

## ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន និងលោកជំទាវ

## ព្រមទាំងក្រុមគ្រួសារ

ឯកឧត្តមសន្តិបណ្ឌិត និងលោកជំទាវ ជាទីគោរព!

ខ្ញុំនិងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា ឧបាសិកា **នេត សុគន្ធ** ដែលត្រូវជាបងស្រីបង្កើតរបស់ឯកឧត្តមសន្តិបណ្ឌិត បានទទួលមរណភាពនាថ្ងៃចន្ទ ៧រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦ វេលាម៉ោង ១៣:៥៧នាទី ក្នុងជន្មាយុ៧៨ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ឧបាសិកា **នេត សុគន្ធ** មិនត្រឹមតែជាការបាត់បង់នូវបងស្រី ភរិយា មាតា អ៊ំស្រី និងជីដូនដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តម និងព្រហ្មវិហារធម៌ចំពោះក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់នូវពុទ្ធសាសនូបត្ថម្ភក៍មួយរូប ប្រកបដោយក្តីមេត្តាករុណា ដែលតែងតែលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី សទ្ធាជ្រះថ្លាដ៏វិសេសថ្លៃថ្លាក្នុងការចូលរួមចំណែកលើកតម្កើងនូវវិស័យព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយឯកឧត្តមសន្តិបណ្ឌិត និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជះបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធសពរបស់ឧបាសិកា **នេត សុគន្ធ** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំពីខ្ញុំនិងភរិយា។

ថ្ងៃចន្ទ ៧រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៦

**នាយឧត្តមសេនីយ៍ ទៀ សីហា**